# រូបភាពជំនួយអំពី
# នីតិវិធីតុលាការសំរាប់កុមារ




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes
stops child exploitation

# ជំនួបប្រឹក្សាយោបល់ជាមួយកុមារ និងមេធាវីរបស់ខ្លួន

១. មេធាវីគួរធ្វើការណែនាំខ្លួន និងបង្កើតទំនាក់ទំនងជិតស្និទ្ធិជាមួយកុមាររងគ្រោះ មុននឹងចាប់ផ្តើមផ្តល់ប្រឹក្សាផ្នែកច្បាប់។

២. មេធាវីគួរប្រាប់កុមារថា ពួកគេមានសិទ្ធិទទួលបាននូវសេវាផ្នែកច្បាប់ ដោយឥតគិតកម្រៃ។

៣. មេធាវីគួរអនុញ្ញាតឲ្យកុមាររងគ្រោះបញ្ចេញទស្សនៈផ្ទាល់ខ្លួនដោយសេរីអំពីជម្រើសនៃសេវាកម្មផ្នែកច្បាប់ ការចូលរួមនីតិវិធីតុលាការសំណូមពរ តម្រូវការចាំបាច់ ឬក្តីបារម្ភផ្សេងៗដែលកុមារមាន។ មេធាវីគួរគោរពតាមការសម្រេចចិត្ត និងទស្សនៈរបស់កុមារ និងត្រូវធ្វើសកម្មភាពការពារឧត្តមប្រយោជន៍របស់កុមារ ។

៤. មេធាវីគួរប្រាប់កុមារ និងអាណាព្យាបាលអំពីព្យសនកម្មនានាបណ្តាលមកពីការរំលោភបំពានផ្លូវភេទ (ឧទាៈ ការប៉ះពាល់ខាងរូបកាយ ខាងផ្លូវចិត្ត និងខាងសម្ភារៈ)។

៥. មេធាវីគួរព្យាយាមពន្យល់ឲ្យបានច្បាស់លាស់ ពេញលេញ អំពីនីតិវិធីតុលាការដល់កុមារ និងអាណាព្យាបាល ដោយប្រើប្រាស់ភាសា និងកាយវិការសមស្របជាមួយអាយុ និងចំណេះដឹងរបស់ពួកគេ។

៦. មេធាវីគួរពន្យល់ពីសិទ្ធិនានារបស់កុមាររងគ្រោះនៅពេលផ្តល់ការបំភ្លឺ (ឧទាៈ សិទ្ធិទទួលបានសវនាការជាសាធារណៈ សិទ្ធិស្នើសុំប្រើប្រាស់របាំង ឬការសន្ទនាតាមរយៈទូរទស្សន៍ សិទ្ធិបដិសេធចៅក្រម សិទ្ធិបដិសេធការឆ្លើយ និងសិទ្ធិធ្វើសំណូមពរ ជាដើម)។

៧. មេធាវីគួរប្រាប់កុមារ អាណាព្យាបាល ឬ បុគ្គលិកសង្គមកិច្ច អំពីពេលវេលា និងទីកន្លែងជាក់លាក់ដែលកុមារ ឬ អាណាព្យាបាល ត្រូវចូលរួមបំភ្លឺក្នុងនីតិវិធីតុលាការ។

៨. មេធាវីត្រូវណែនាំកុមារឲ្យនិយាយតែការពិត និងរៀបរាប់ដោយពាក្យពេចន៍ផ្ទាល់ខ្លួនអំពីទង្វើដែលបានកើតឡើងចំពោះខ្លួនគេ។

៩. មេធាវីគួរប្រើសំណួរបើក និងជៀសវាងសួរសំណួរមានលក្ខណៈនាំមុខ ឬបង្ខំ ឬដដែលៗ ។

១០. មេធាវីត្រូវជួយកុមារឲ្យមានទំនុកចិត្ត ឬបាត់ការភ័យខ្លាច មុននឹងអនុញ្ញាតឲ្យពួកគេចូលរួមបំភ្លឺ។



ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# សមាសភាពអង្គសវនាការនៃសាលាដំបូង

១. មេធាវីគួរពន្យល់កុមារ និងអាណាព្យាបាល ពីសមាសភាពអង្គសវនាការ។

២. សមាសភាពអង្គសវនាការរួមមានៈ

ក). ចៅក្រម ៣ (បី) រូប ជាក្រុមប្រឹក្សាជំនុំជម្រះ មានសិទ្ធិសម្រេចសេចក្ដីរួមគ្នា ក្នុងករណីបទឧក្រិដ្ឋព្រមទាំង បទមជ្ឈិម និង បទលហុ ដែលជាប់ទាក់ទង។

ខ). តំណាងអយ្យការ ១ (រូប) ជាព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារង។

គ). ក្រឡាបញ្ជីសវនាការ ១ (រូប) ជាអ្នកកត់កំណត់ត្រា ការពិភាក្សាដេញដោល នាពេលសវនាការ។

ឃ). មេធាវីរបស់កុមារ និង ដើមបណ្ដឹងរដ្ឋប្បវេណី។

ង). មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ច). បុគ្គលិកសង្គមកិច្ច អាណាព្យាបាល អ្នកសារព័ត៌មាន និងសាធារណជន ដែលមានសិទ្ធិចូលរួមស្ដាប់ និង សង្កេតការណ៍ នាពេលសវនាការ។

៣. មេធាវីគួរប្រាប់កុមារពីទីតាំង(កន្លែងអង្គុយ)របស់ចៅក្រមជំនុំជម្រះ តំណាងអយ្យការ ក្រឡាបញ្ជី មេធាវី សាក្សី អ្នកជំនាញ ជនជាប់ចោទ កងការពារ និងវត្តមានសាធារណជនក្នុងបន្ទប់សវនាការ។

៤. មេធាវីគួរប្រាប់កុមារ និងអាណាព្យាបាល អំពីបទបញ្ជាផ្សេងៗ ក្នុងបន្ទប់សវនាការ។





ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# ការសាកសួរកុមារដោយចៅក្រមជំនុំជម្រះ

១. មេធាវីគួរស្នើសុំចៅក្រមជំនុំជម្រះអោយដំណើរការសវនាការជាអសាធារណៈ ដើម្បីរក្សាកិត្តិយស ភាពថ្លៃថ្នូរ និងកាត់បន្ថយភាព អៀនខ្មាស់ និងការភ័យខ្លាចរបស់កុមាររងគ្រោះ។

២. មេធាវីគួរប្រាប់កុមារ និងអាណាព្យាបាលអំពីតួនាទីរបស់ចៅក្រមជំនុំជម្រះ ដូចខាងក្រោម៖

ក). ចៅក្រមជំនុំជម្រះ ធ្វើការសាកសួរ និងស្តាប់ការបំភ្លឺរបស់ជនរងគ្រោះ។

ខ). ចៅក្រមជំនុំជម្រះ អាចស្នើសុំឲ្យកុមារបញ្ជាក់ពីអាយុ និងបង្ហាញភស្តុតាងនានា ប្រសិនបើមាន។

៣. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចស្នើសុំឲ្យចៅក្រមជំនុំជម្រះចោទសួរឡើងវិញ ចំពោះសំណួរណាដែលខ្លួនមិនយល់ច្បាស់។

៤. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចសុំមិនឆ្លើយសំណួររបស់ចៅក្រមជំនុំជម្រះដែលបានចោទសួរ។

៥. មេធាវីគួរលើកទឹកចិត្តកុមារឲ្យនិយាយតែការពិតប្រាប់ចៅក្រមជំនុំជម្រះ។

៦. មេធាវីគួរជួយពន្យល់កុមារអំពីសំណួរទាំងឡាយរបស់ចៅក្រមជំនុំជម្រះដែលខ្លួនពិបាកយល់។

៧. មេធាវីគួរស្នើសុំឲ្យចៅក្រមជំនុំជម្រះបញ្ឈប់ការសួរមួយរយៈ ប្រសិនបើកុមារមានអារម្មណ៍តានតឹង ធុញទ្រាន់ ឬប៉ះទង្គិចផ្លូវចិត្ត ដែលធ្វើឲ្យកុមារមិនអាចឆ្លើយបំភ្លឺបាន។

៨. មេធាវីត្រូវស្នើសុំឲ្យបុគ្គលិកសង្គមផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្តភ្លាមដល់កុមារ នៅពេលពួកគេជួបស្ថានភាពដូចរៀបរាប់ខាងលើ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes
stops child exploitation

# ការសាកសួរកុមារដោយតំណាងអយ្យការ

១. មេធាវីត្រូវប្រាប់កុមាររងគ្រោះអំពីតួនាទីរបស់តំណាងអយ្យការ ដែលមានវត្តមានក្នុងពេលសវនាការ។

២. តំណាងអយ្យការមានតួនាទីដូចខាងក្រោមះ

ក). ជាអ្នកចោទប្រកាន់ជនសង្ស័យ

ខ). ជាអ្នកសន្និដ្ឋានប្តឹងសុំទៅតុលាការ ឲ្យអនុវត្តច្បាប់

គ). ជាអ្នកសាកសួរ និងស្តាប់ការបំភ្លឺរបស់កុមារ

៣. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចស្នើសុំឲ្យតំណាងអយ្យការធ្វើការចោទសួរឡើងវិញ ចំពោះសំណួរណាដែលខ្លួនមិនយល់ច្បាស់។

៤. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចសុំមិនឆ្លើយសំណួររបស់តំណាងអយ្យការដែលបានចោទសួរ។

៥. មេធាវីគួរលើកទឹកចិត្តកុមារឲ្យនិយាយតែការពិតប្រាប់តំណាងអយ្យការ។

៦. មេធាវីគួរជួយពន្យល់កុមារអំពីសំណួរទាំងឡាយរបស់តំណាងអយ្យការដែលខ្លួនពិបាកយល់។

៧. មេធាវីគួរស្នើសុំឲ្យតំណាងអយ្យការបញ្ឈប់ការសួរមួយរយៈ ប្រសិនបើកុមារមានអារម្មណ៍តានតឹង ធុញទ្រាន់ ឬប៉ះទង្គិចផ្លូវចិត្ត ដែលធ្វើឲ្យកុមារមិនអាចឆ្លើយបំភ្លឺបាន។

៨. មេធាវីត្រូវស្នើសុំឲ្យបុគ្គលិកសង្គមផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្តភ្លាមដល់កុមារ នៅពេលពួកគេជួបស្ថានភាពដូចរៀបរាប់ខាងលើ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# ការសាកសួរកុមារដោយមេធាវីការពារជនជាប់ចោទ

១. មេធាវីត្រូវប្រាប់កុមារអំពីតួនាទីរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងការសាកសួររបស់ពួកគេនៅពេលសវនាការ។

២. មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទមានតួនាទីដូចខាងក្រោមៈ

ក). ធ្វើការសាកសួរកុមារ នៅពេលទទួលបានការអនុញ្ញាតពីចៅក្រមជំនុំជម្រះ។

ខ).សួរកុមារនូវសំណួរទាំងឡាយទាក់ទងនឹងរឿងហេតុ។

៣. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចស្នើសុំឲ្យមេធាវីការពារជនជាប់ចោទធ្វើការចោទសួរឡើងវិញ ចំពោះសំណួរណាដែលខ្លួនមិនយល់ច្បាស់។

៤. មេធាវីគួរប្រាប់កុមារថា ខ្លួនអាចសុំមិនឆ្លើយតបនូវសំណួររបស់មេធាវីការពារសិទ្ធិជនជាប់ចោទដែលបានសាកសួរ។

៥. មេធាវីគួរលើកទឹកចិត្តកុមារឲ្យនិយាយតែការពិតប្រាប់មេធាវីការពារសិទ្ធិជនជាប់ចោទ។

៦. មេធាវីគួរជួយពន្យល់កុមារអំពីសំណួរទាំងឡាយរបស់មេធាវីការពារសិទ្ធិជនជាប់ចោទដែលខ្លួនពិបាកយល់។

៧. មេធាវីគួរស្នើសុំឲ្យមេធាវីការពារសិទ្ធិជនជាប់ចោទប្រើពាក្យពេចន៍សមស្របនឹងកម្រិតយល់ដឹងរបស់កុមារ និង មិនត្រូវធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍កុមារឡើយ។

៨. មេធាវីគួរស្នើសុំឲ្យមេធាវីការពារសិទ្ធិជនជាប់ចោទបញ្ឈប់ការសួរមួយរយៈ ប្រសិនបើកុមារមានអារម្មណ៍តានតឹង ធុញទ្រាន់ ឬប៉ះទង្គិចផ្លូវចិត្តដែលធ្វើឲ្យកុមារមិនអាចឆ្លើយបំភ្លឺបាន។

៩. មេធាវីត្រូវស្នើសុំឲ្យបុគ្គលិកសង្គមផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្តភ្លាមដល់កុមារ នៅពេលពួកគេជួបស្ថានភាពដូចរៀបរាប់ខាងលើ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# ការសាកសួរកុមារដោយមេធាវីរបស់កុមារ

១. មេធាវីរបស់កុមារមានតួនាទី ដូចខាងក្រោម៖

ក). សាកសួរកុមារបញ្ជាក់អំពីអង្គហេតុឡើងវិញនៅពេលសវនាការ

ខ). ស្នើសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទ

២. មេធាវីគួររំលឹកប្រាប់កុមារថា ពួកគេត្រូវនិយាយតែការពិត អំពីរឿងហេតុដែលបានកើតឡើងចំពោះខ្លួនដោយមិនចាំបាច់ភិតភ័យ។

៣. មេធាវីរបស់កុមារ ត្រូវសាកសួរដោយប្រើសំណួរសមរម្យ និងសមស្របទៅតាមអាយុ កម្រិតយល់ដឹងរបស់កុមារ និងមិនត្រូវប្រើសំណួរដែលធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍កុមារឡើយ។

៤. មេធាវីរបស់កុមារ គួរសួរសំណួរបើក ដោយប្រើពាក្យពេចន៍ងាយយល់ និងអាចសួរសំណួរមួយចំនួនឡើងវិញដើម្បីបញ្ជាក់ពីអង្គហេតុ។

៥. មេធាវីរបស់កុមារត្រូវស្នើសុំអង្គសវនាការឲ្យគោរពសិទ្ធិ និង ភាពឯកជនរបស់កុមារ គួរសួរសំណួរសមរម្យ និង ព្យាយាមការពារកុមារពីបរិយាកាសនានា ដែលធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់កុមារនៅពេលសវនាការ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# ការប្រើរបាំងក្នុងបន្ទប់សវនាការ

១. មេធាវីគួរស្នើសុំដល់ចៅក្រមជំនុំជម្រះ ប្រើប្រាស់របាំងនៅក្នុងបន្ទប់សវនាការ ដើម្បីកុំឲ្យកុមារមានអារម្មណ៍ភ័យខ្លាច នៅពេលឃើញមុខជនជាប់ចោទ។

២. មេធាវីគួរប្រាប់កុមារពីការចូលរួមរបស់ជនជាប់ចោទក្នុងបន្ទប់សវនាការ ហើយជនជាប់ចោទមានសិទ្ធិក្នុងការស្តាប់ការបំភ្លឺរបស់កុមារនៅក្នុងបន្ទប់សវនាការ។

៣. មេធាវីគួរស្នើសុំឲ្យដាក់របាំងនៅទីតាំងសមរម្យដែលមានចៅក្រមជំនុំជម្រះ តំណាងអយ្យការ និងមេធាវី អាចមើលកុមារឃើញ។

៤. មេធាវីគួរប្រាប់កុមារថា ជនជាប់ចោទមិនអាចសាកសួរកុមារដោយផ្ទាល់បានទេ។

៥. មេធាវីគួរស្នើសុំឲ្យក្រឡាបញ្ជីរៀបចំដាក់របាំងក្នុងបន្ទប់សវនាការ មុនពេលជនជាប់ចោទចូលក្នុងបន្ទប់សវនាការ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes
stops child exploitation

# សវនាការអសាធារណៈ ដោយមានវត្តមាន
# អាណាព្យាបាល ឬបុគ្គលិកសង្គមកិច្ច

១. មេធាវីគួរស្នើសុំចៅក្រមជំនុំជម្រះឲ្យដំណើរការសវនាការជាអសាធារណៈ។

២. មេធាវីគួរស្នើសុំដល់ចៅក្រមជំនុំជម្រះឲ្យអាណាព្យាបាល ឬ បុគ្គលិកសង្គមកិច្ចមានវត្តមាននៅក្បែរកុមារ ដើម្បីកុំឲ្យកុមារមានការភ័យខ្លាច។

៣. មេធាវីត្រូវស្នើសុំឲ្យអាណាព្យាបាល ឬ បុគ្គលិកសង្គមផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្តភ្លាមដល់កុមារ នៅពេលពួកគេមានអារម្មណ៍ភ័យខ្លាចនៅក្នុងបន្ទប់សវនាការ។

៤. មេធាវីគួរប្រាប់កុមារថា នៅពេលចៅក្រមជំនុំជម្រះសាកសួរខ្លួន អាណាព្យាបាល ឬ បុគ្គលិកសង្គមកិច្ចមិនអាចឆ្លើយជំនួសកុមារបានឡើយ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

# សចនាការជាសាធារណៈ

១. មេធាវីគួរស្នើសុំដល់ចៅក្រមជំនុំជម្រះឲ្យប្រើប្រាស់របាំងនៅក្នុងបន្ទប់សវនាការ ដើម្បីកុំឲ្យកុមារមានអារម្មណ៍ភ័យខ្លាច នៅពេលឃើញមុខជនជាប់ចោទ។

២. មេធាវីគួរស្នើសុំឲ្យអាណាព្យាបាល ឬបុគ្គលិកសង្គមកិច្ចនៅក្បែរកុមារជានិច្ច។

៣. មេធាវីគួរប្រាប់កុមារថា ទោះបីមានវត្តមានសាធារណជនក្នុងបន្ទប់សវនាការក៏ដោយ ក៏ពួកគេមិនអាចសាកសួរកុមារបានដែរ។

៤. មេធាវីគួរព្យាយាមការពារការផ្សព្វផ្សាយអត្តសញ្ញាណរបស់កុមាររងគ្រោះ។




ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes
stops child exploitation

# ការសាកសួរកុមារពីបន្ទប់អនីតិជន តាមរយៈបណ្តាញទូរទស្សន៍

១. មេធាវីគួរស្នើសុំដល់ចៅក្រមជំនុំជម្រះឲ្យប្រើប្រាស់បន្ទប់អនីតិជន និងស្នើសុំឲ្យកុមារបំភ្លឺតាមរយៈបណ្តាញទូរទស្សន៍ ដើម្បីកុំឲ្យកុមារមានអារម្មណ៍ភ័យខ្លាច នៅពេលឃើញមុខជនជាប់ចោទ និងសាធារណជន។

២. មេធាវីគួរស្នើសុំដល់ចៅក្រមជំនុំជម្រះឲ្យអាណាព្យាបាល ឬ បុគ្គលិកសង្គមកិច្ចមានវត្តមានក្នុងបន្ទប់អនីតិជន ក្នុងអំឡុងពេលដែលកុមារបំភ្លឺតាមរយៈបណ្តាញទូរទស្សន៍។

៣. មេធាវីគួរប្រាប់កុមារឲ្យដឹងថា កុមារអាចស្តាប់សំណួររបស់ចៅក្រមជំនុំជម្រះ តំណាងអយ្យការ មេធាវី តាមរយៈទូរទស្សន៍ និងការឆ្លើយតបរបស់កុមារតាមរយៈឧបករណ៍សម្លេងដែលមានស្រាប់នៅលើតុ ក្នុងបន្ទប់អនីតិជន។

៤. មេធាវីគួរប្រាប់កុមារថា កុមារអាចមើលឃើញទិដ្ឋភាពទាំងស្រុងពីក្នុងបន្ទប់សវនាការតាមរយៈបណ្តាញទូរទស្សន៍នេះ។

៥. មេធាវីគួរប្រាប់កុមារថា មានតែចៅក្រមជំនុំជម្រះ តំណាងអយ្យការ និងមេធាវី អាចមើលឃើញកុមារតាមរយៈទូរទស្សន៍បាន។



ផលិតដោយ៖ APLE

ឧបត្ថម្ភដោយ៖ terre des hommes stops child exploitation

**ផលិតដោយ៖**

PRODUCED BY:

អង្គការសកម្មភាពដើម្បីកុមារ (APLE)
ក្រោមការផ្តល់ប្រឹក្សាយោបល់ជាមួយផ្នែកជំនួយផ្លូវច្បាប់
នៃអង្គការសកម្មភាពដើម្បីកុមារ

Action Pour Les Enfants (APLE)
in consultation with the Legal Department
of APLE Cambodia

**ឧបត្ថម្ភថវិកាដោយ៖**

FUNDED BY:

អង្គការដែនដីមនុស្ស-ហូឡង់ដ៍

Terre des Hommes Netherlands

APLE

terre des hommes
stops child exploitation

សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការដែនដីមនុស្ស-ហូឡង់ដ៍ សំរាប់ការគាំទ្រថវិកាក្នុងកិច្ចដំណើរការគំរោងកម្មវិធី និងការបោះពុម្ពផ្សាយ
Profound thanks to Terre des Hommes Netherlands for funding the project and distribution